ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ..........................

# ញត្តិថ្កោលទោស

កាលពីពេលថ្មីៗនេះ ទណ្ឌិត សម រង្ស៊ី ដែលរត់គេចពីការតាមចាប់ខ្លួនរបស់តុលាការកម្ពុជា បានប្រកាសអំពីផែនការថ្មីផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០២៣ ខាងមុខនេះ ថែមទាំងបានញុះញង់ ឱ្យប្រជាពលរដ្ឋ និងកងកម្លាំងប្រដាប់អាវុធ ប្រឆាំងរាជរដ្ឋាភិបាល។

អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្កា និងប្រឆាំងដាច់ខាតចំពោះអំពើទុច្ចរិត ក្បត់ជាតិ និងការរំលោភបំពានច្បាប់ដ៏ធ្ងន់ធ្ងរ របស់ទណ្ឌិតខិលខូចរូបនេះ ដែលមានចេតនាបំផ្លិចបំផ្លាញដល់សន្តិភាព ស្ថិរភាព និងសេចក្តីសុខរបស់ប្រជាជនកម្ពុជា។

អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការការពាររាជរដ្ឋាភិបាលស្របច្បាប់ដឹកនាំដោយ សម្តេចតេជោ ហ៊ុន សែន ឱ្យខាងតែបាន និងត្រៀមខ្លួនរួចជាស្រេច ក្នុងការអនុវត្តតាមច្បាប់ និងបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការកម្ទេចចោលនូវ ជនក្បត់ជាតិ៣ជំនាន់ សម រង្ស៊ី និងបក្ខពួក ដែលប៉ុនប៉ងធ្វើបដិវត្តពណ៌ បង្កចលាចលក្នុងសង្គមកម្ពុជា ម្តងហើយម្តងទៀត។

អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ក៏សូមស្នើដល់អាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការឱ្យធ្ងន់ធ្ងរចំពោះអំពើក្បត់ជាតិ៣ជំនាន់របស់ ទណ្ឌិត សម រង្ស៊ី ហើយសូមស្នើដល់ស្ថាប័នតុលាការ អនុវត្តទោសលើជននេះតាមច្បាប់ ឱ្យបានធ្ងន់ធ្ងរបំផុត ដោយគ្មានលើកលែង៕

ថ្ងៃអង្គារ, ៨រោជ ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២